# ធម្មាធិបតេយ្យ

៚ ❃ ៚

## ១_សេចក្តីផ្តើម:

បន្ទាប់ពីភាពជាប់គាំងផ្នែកនយោបាយអស់រយៈពេលជិតមួយឆ្នាំមកនេះ ទីបំផុតគណបក្សនយោបាយខ្មែរពីរបានឈានដល់កិច្ចព្រមព្រៀងបង្កើតរដ្ឋាភិបាលចំរុះថ្មីដែលអនុម័តដោយការបោះឆ្នោតសភាកាលពីថ្ងៃទី១៥ កក្កដា ឆ្នាំ ២០០៤។ ប៉ុន្តែការបង្កើតរដ្ឋាភិបាលថ្មីនេះមានភាពចំរូងចំរាសជាថ្មីម្តងទៀតដោយសារការបោះឆ្នោតអនុម័តលើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ដែលអនុញ្ញាតអោយមានការបោះឆ្នោតកញ្ចប់។ ព្រះមហាក្សត្រពុំបានអនុម័តលើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមនេះទេ ប៉ុន្តែអនុប្រធានទី២ ព្រឹទ្ធសភាជាអ្នកអនុម័តជំនួសទៅវិញ។

ថ្វីត្បិតតែមានដំណើរថយក្រោយបែបនេះមែន អង្គការក្រៅរដ្ឋាភិបាលសូមអំពាវនាវដល់រាជរដ្ឋាភិបាលនិងសភាថ្មីពង្រឹងស្ថាប័នទាំងនេះក្នុងន័យដើម្បីការពារធម្មាធិបតេយ្យនិងសិទ្ធិមនុស្សនៅកម្ពុជានិងលើកស្ទួយដល់ការគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

## ២_ បញ្ហាជាគន្លឹះ

អង្គការក្រៅរដ្ឋាភិបាលសូមរំលឹកដល់អ្នកនយោបាយអំពីភារកិច្ចរបស់ខ្លួនចំពោះប្រជាពលរដ្ឋដោយគោរពតាមកិច្ចសន្យាដែលបានធ្វើក្នុងអំឡុងយុទ្ធនាការបោះឆ្នោតជាតិឆ្នាំ២០០៣និងចំនុចទាំងឡាយនៅក្នុងកិច្ចព្រមព្រៀងមុនពេលបង្កើតរាជរដ្ឋាភិបាលថ្មីនិងសូមអំពាវនាវដល់អ្នកនយោបាយចាត់វិធានការអោយបានម៉ឺងម៉ាត់ ដើម្បីកម្ពុជាអាចដោះស្រាយបញ្ហាភាពក្រីក្រនិងអំពើពុករលួយនិងបង្កើតប្រព័ន្ធច្បាប់មួយដ៏ប្រសើរដែលធានាដល់ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យសេរីនិងសិទ្ធិមនុស្ស ។

### ការកែទំរង់ស្ថាប័នផ្សេងៗ

អង្គការក្រៅរដ្ឋាភិបាលទទួលស្គាល់ការអភិវឌ្ឍន៍និងការផ្សព្វផ្សាយយុទ្ធសាស្ត្រកំណែទំរង់ច្បាប់និងតុលាការ ដែលបោះពុម្ពផ្សាយដោយរដ្ឋាភិបាលនៅឆ្នាំ ២០០៣។ អង្គការក្រៅរដ្ឋាភិបាលទន្ទឹងរង់ចាំមើលការអនុវត្តប្រកបដោយប្រសិទ្ធិភាពនិងសក្តិសិទ្ធទៅលើកំណែទំរង់នៅក្នុងវិស័យនេះ។

ស្ថាប័នសំខាន់ៗមួយចំនួនធំដែលមានស្រាប់នាពេលបច្ចុប្បន្នគួតែត្រូវកែទំរង់រួមមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ គណកម្មការសុរិយោដី និង អាជ្ញាធរសវនកម្មជាតិ ។មុខតំណែងរបស់ឥស្សរជនទាំងនេះត្រូវតែសរសេរបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញដើម្បីអោយមានការធានាដោយភាពស្របច្បាប់និងស្ថេរភាព។ ជាគោលការណ៍ ពួកគេចាំបាច់ត្រូវមានភាពឯករាជ្យ និង មិនស្ថិតក្នុងគណៈបក្សនយោបាយ ហើយមានសមាជិកភាពដែលចាំបាច់ត្រូវ បង្កើតគណៈកម្មាធិការជ្រើសរើសដើម្បីតែងតាំងសមាជិកនៃស្ថាប័នទាំងនេះ ។គេត្រូវតែបំពេញតួនាទីប្រកបដោយ សមត្ថភាព និង គួរអោយជឿទុកចិត្តបាន ដែលត្រូវពង្រឹងធនធានមនុស្សប្រកបដោយគុណភាព បុគ្គលិកមាន ជំនាញ និង ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ។ ស្ថាប័នទាំងនេះ ចាំបាច់ត្រូវត្រួតពិនិត្យដោយយន្តការសភា និងព្រឹទ្ធសភាតាមវិធីមួយដែលមានលក្ខណៈដូចគ្នានឹងគណៈកម្មការទាំង ៩ របស់រដ្ឋ សភា និងព្រឹទ្ធសភា ។

ស្ថាប័ន និង ច្បាប់ដែលមិនទាន់មាន

គណៈកម្មការថ្មីនានា ដែលយ៉ាងតិចណាស់រួមមាន គណៈកម្មការប្រឆាំងអំពើពុករលួយ និងគណៈកម្មការសិទ្ធិ មនុស្សជាតិ គួរតែបង្កើតឡើងអោយបានឆាប់តាមដែលអាចធ្វើទៅបាន តាមស្តង់ដារអន្តរជាតិ មានន័យថា គណៈកម្មការទាំងនេះត្រូវតែឯករាជ្យ មិនមានការពាក់ព័ន្ធនយោបាយ មានសមត្ថភាពនិង គួរអោយជឿទុកចិត្តបាន។

រាជរដ្ឋាភិបាលថ្មីត្រូវជំរុញឱ្យមានការបង្កើតច្បាប់ថ្មី ដើម្បីធានាថា ប្រព័ន្ធច្បាប់ទាំងនោះ អាចដោះស្រាយបញ្ហា ធ្ងន់ធ្ងរដែលកើតមានជាបន្ត ។ ច្បាប់ថ្មីទាំងនេះត្រូវចាត់ទុកជាអាទិភាព រួមមានក្រមព្រហ្មទណ្ឌថ្មី ក្រមរដ្ឋប្បវេណី ច្បាប់នីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីសិទ្ធិទទួលពតិមាន ច្បាប់ស្តីពីក្របខ័ណ្ឌស៊ីវិលនិងប្រព័ន្ធផ្នែកបណ្តឹងរដ្ឋបាល ។ត្រូវបង្កើតច្បាប់ដើម្បីដំណើការស្ថាប័នសំ

ខាន់ៗនិងផ្តល់ក្របខ័ណ្ឌមួយសំរាប់អភិបាលកិច្ចល្អនិងគណនេយ្យភាព នៅក្នុងផ្នែកសាធារណៈ។ ច្បាប់បាតុកម្មបច្ចុប្បន្នគួរត្រូវជំនួសដោយច្បាប់ថ្មី ។គួរមានច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញាដែលយ៉ាងហោចណាស់អាចធានាអំពីសុចរិតភាពនៃដំណើការតែងតាំង និង ធានាថាគ្រប់ចៅក្រមទាំងអស់មិនពាក់ព័ន្ធនឹងនយោបាយនិងទទួលបាននូវភាពឯករាជ្យផ្ទាល់ខ្លួននិងផ្នែកតុលាការ ដោយមិនរងនូវឥទ្ធិពលផ្ទាល់ខ្លួន ឬ ផលប្រយោជន៏ឯកជន។ ជាងនេះទៅទៀត រដ្ឋាភិបាលថ្មីចាំបាច់ត្រូវបង្កើត លក្ខន្តិកៈកងកំលាំងប្រដាប់អាវុធ និង មន្ត្រីរាជការស៊ីវិល។

លក្ខន្តិកៈកងកំលាំងប្រដាប់អាវុធនិង មន្ត្រីរាជការស៊ីវិលគួរតែធ្វើវិសោធនកម្ម ដើម្បីធានាពីភាពមិនលំអៀងផ្នែកនយោបាយនៃមន្ត្រីរាជការស៊ីវិលនិងធានាអំពីសុចរិតភាពនិងគណនេយ្យភាពព្រមទាំងវិធានត្រឹមត្រូវសំរាប់ជ្រើសរើសនិងតំលើងថានៈតាមគុណសម្បត្តិ។
លក្ខន្តិកៈកងកំលាំងប្រដាប់អាវុធនិង ច្បាប់វិន័យសំរាប់នគរបាលគួរធ្វើវិសោធនកម្ម ដើម្បីធានាថានគរបាលមិនមកមែនជាសមាជិកគណបក្សនយោបាយនិងមិនជាប់ពាក់ព័ន្ធនឹងនយោបាយ ។

ច្បាប់ទាំងឡាយត្រូវតែឆ្លងការអនុម័ត ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរជាក់លាក់ដែលបន្តកើតមាននៅកម្ពុជា ។អាទិភាពខ្ពស់គួរផ្តល់ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយដែលចាំបាច់ត្រូវដោះស្រាយដោយច្បាប់មួយជាកញ្ចប់( លក្ខន្តិកៈ ការធ្វើវិសោធន៍កម្មទៅលើច្បាប់ដែលមានស្រាប់ ។ល ។) ច្បាប់ប្រឆាំងការជួញដូរមនុស្ស និង ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ ។ ច្បាប់ប្រឆាំងការជួយដូរមនុស្ស ចាំ បាច់ត្រូវធ្វើវិសោធនកម្មដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ។ ដើម្បីធានាអោយស្ថានភាពនយោបាយមានតំលាភាពច្រើន ចាំបាច់ត្រូវបង្កើតច្បាប់ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយនិងជំរុញឱ្យមានការប្រកាសទ្រព្យសម្បត្តិ ( ស្ថិតក្នុងជំពូកមួយនៃច្បាប់ប្រឆាំងអំពើពុករលួយ) ដែលធានាថាគ្រប់សមាជិករដ្ឋាភិបាលទាំងអស់ត្រូវតែប្រកាសពីទ្រព្យ សម្បត្តិរបស់ខ្លួនមុនចូលកាន់តំណែង ។

ជាចុងក្រោយចាំបាច់ត្រូវបង្កើតច្បាប់ស្តីពីសមាជាតិអោយបានឆាប់ដើម្បីឆ្លើយតបទៅនឹងការសន្យាដ៏ូលដែលបានចែងនៅក្នុងជំពូកទី៧នៃរដ្ឋធម្មនុញ្ញ ។ដោយអនុញ្ញាតអោយប្រជាពលរដ្ឋ ទទួលបាននូវពត៌មានដោយផ្ទាល់ស្តីពីបញ្ហាផ្សេង១ពាក់ព័ន្ធដល់ផលប្រយោជន៍ជាតិនិងលើកឡើងពីបញ្ហានិងសំណូមពរដល់អាជ្ញាធររដ្ឋធ្វើការដោះស្រាយ ។សមាជជាតិដ៏មានប្រសិទ្ធិភាពមួយនឹងគាំទ្រដល់ការពង្រឹងនយោបាយ នៅគ្រប់លំដាប់ថ្នាក់ក្នុងសង្គម និងបង្កើនការចូល រួមពីសាធារណជន នៅក្នុងជីវភាពនយោបាយរបស់ប្រទេស និងមានតម្លាភាពនៅក្នុងដំណើរការសាធារណៈ ។

## <u>**ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ**</u>

ព្រឹត្តិការណ៍ឆ្នាំ ២០០៤ បានបង្ហាញអោយឃើញពីការព្រួយបារម្ភចំពោះ កង្វះខាតនៃការគោរពរដ្ឋធម្មនុញ្ញ ពីសំណាក់អ្នកនយោបាយ និងអ្នកច្បាប់ខ្មែរ ។

ការមិនគោរពរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៅក្នុងប្រទេស គឺបញ្ជាក់អោយឃើញថាប្រទេសកម្ពុជាបំពេញមុខងារក្រោមធម្មាធិបតេយ្យនៅមានក៏រិត ។ អង្គការក្រៅរដ្ឋាភិបាលកាលពីមុនធ្លាប់បានផ្តល់អនុសាសន៍លើ ការធ្វើវិសោធនកម្ម ដូចជាតំរូវអោយមានសំលេងភាគច្រើនធម្មតាដើម្បីបោះឆ្នោតផ្តល់សំលេងទុកចិត្តបង្កើតរាជរដ្ឋា ភិបាលបង្ការពីវិបត្តិនយោបាយដែលកើតឡើងបន្ទាប់ពីរៀងរាល់ការបោះឆ្នោតជាតិចាប់តាំងពីមានកិច្ចព្រមព្រៀង សន្តិភាពក្រុងប៉ារីស ។ ប៉ុន្តែការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាចំបង បែបនេះ មិនគួរធ្វើដើម្បីកាលានុវត្តន៍ផ្នែកនយោ បាយ នោះទេ ផ្ទុយទៅវិញគេគួរតែអនុវត្តតាម ការពិភាក្សាពិគ្រោះយោបល់ និងធ្វើតែក្នុងអំឡុងអណត្តិរបស់រាជរដ្ឋាភិបាលសុទ្ធសាធ ។ គួរផ្តល់ការយកចិត្តទុកដាក់ជាសំខាន់ទៅលើការបំពេញតំរូវការចាំបាច់នៅក្នុងរដ្ឋធម្មនុញ្ញដែលមានស្រាប់ ដូចជាការបង្កើតសមាជជាតិដូចបានលើកឡើងខាងលើ ។

## ក្រមសីលធមិ

យ៉ាងហោចណាស់ក៏មានចំនុចបីដែរដែលត្រូវពិចារណាៈ

- ទីមួយៈ ក្រមសីលធមិរបស់ចៅក្រម និង ព្រះរាជអាជ្ញា ដែលត្រូវបង្កើតឡើងដោយសមាគម វិជ្ជាជីវៈរបស់ខ្លួន ផ្អែកលើគោលការណ៍ដូចដែលបានចែងក្នុងរដ្ឋ ធម្មនុញ្ញ)
- ទីពីរៈ ក្រមសីលធមិសំរាប់មន្ត្រីរាជការស៊ីវិល ( ដែលគួរអនុម័តតាមទំរង់ច្បាប់)
- និងទីបីៈ ក្រមសីលធមិ របស់មន្ត្រីមុខងារសាធារណៈ ( សមាជិករបស់រាជរដ្ឋាភិបាល និង តំណាងរាស្ត្រជាប់ឆ្នោត) ជាគោលការណ៍ដែលគួរអនុម័ត តាមច្បាប់រដ្ឋធម្មនុញ្ញ ( ជាពិសេស នៅពេលដែលមានវិសមិតភាព) ។ ក្រមសីលធមិសំខាន់ណាស់ចំពោះអភិបាលកិច្ច ល្អ និងចាំបាច់នៅក្នុងការបង្កើតគណនេយ្យភាព និង ការទទួលខុសត្រូវ នៅក្នុងរដ្ឋាភិបាល ។ ក្រមសីលធមិទាំងនេះ ត្រូវតែអនុវត្តអោយបានពិតប្រាកដ ។

ភាដើម្បីឱ្យការអនុវត្តន៍ក្រមសីលធមិមានប្រសិទ្ធិព ជាការចាំបាច់ត្រូវបង្កើតយន្តការមួយនៅសភា និងព្រឹទ្ធសភា ដែលតាមរយៈនេះ សមាជិករាជរដ្ឋាភិបាល សភា និង ព្រឹទ្ធសភា អាចត្រូវបានដាក់ទណ្ឌកម្ម ប្រសិនបើគេរំលោភ ក្រមសីលធមិទាំងនេះ ។

## ៣~អនុសាសន៍ ៖

សង្គមស៊ីវិល មានសុទិដ្ឋិនិយមថា គណបក្សជាប់ឆ្នោតទាំងបី និងទទួលយកអនុសាសន៍ខាងក្រោម ដើម្បី ជាប្រយោជន៍ ដល់ប្រទេសជាតិទាំងមូលៈ

- ធ្វើការកែទំរង់ស្ថាប័នដែលមានស្រាប់ដូចជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ក្រុមប្រឹក្សាធម្មនុញ្ញ និង **អាជ្ញាធរ**សវនកម្មជាតិ ដើម្បីធានាថា ស្ថាប័នទាំងនេះ មានភាពឯករាជ្យ តំល្លាភាព មានសមត្ថភាព និង ពង្រឹងមុខតំណែងស្របច្បាប់របស់ខ្លួន តាមរដ្ឋធម្មនុញ្ញ និង បង្កើតប្រព័ន្ធត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាព ។
- បង្កើតស្ថាប័ននានាដូចជាគណៈកម្មការប្រឆាំងអំពើពុករលួយ និងគណៈកម្មការសិទ្ធិមនុស្សជាតិដែល មានលក្ខណៈឯករាជ្យ មិនចូលគណបក្សនយោបាយ មានសមត្ថភាព និង គួរអោយជឿទុកចិត្តបាន ។
- បង្កើត និង គាំទ្រការឆ្លង និង អនុម័តនូវច្បាប់ថ្មី តាមរយៈរដ្ឋសភាជាតិ និង ព្រឹទ្ធសភារួមមាន ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ច្បាប់ក្របខ័ណ្ឌមន្ត្រីរជាការស៊ីវិល ច្បាប់ប្រឆាំងអំពើពុករលួយច្បាប់ទទួលយកពតិមានច្បាប់បាតុកម្ម ច្បាប់ប្រឆាំងអំពើហឹង្សាក្នុង គ្រួសារ និង ច្បាប់ប្រឆាំងការជួញដូរមនុស្ស ។

- បង្កើតច្បាប់ដើម្បីធានាថាស្ថាប័នសំខាន់ៗដូចជាស្ថាប័នតុលាការមិនមានការពាក់ព័ន្ធគណបក្សនយោបាយ ។
- បង្កើតច្បាប់ថ្មី ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង ការប្រកាសទ្រព្យសម្បត្តិ ដែលធានាថាគ្រប់សមាជិករាជរដ្ឋាភិបាលត្រូវតែប្រកាសទ្រព្យសម្បត្តិរបស់ខ្លួនមុនចូលកាន់តំណែង ។
- ធ្វើវិសោធន៍កម្មលើរដ្ឋធម្មនុញ្ញ ដើម្បីគាំទ្រ និង ពង្រឹងដំណើរការនៃការបង្កើតរដ្ឋាភិបាល ដែលមានការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យ រួមមានការអនុញ្ញាតអោយមានការបោះឆ្នោតដោយសំលេងភាគច្រើន ធម្មតានៅក្នុងការបោះឆ្នោតជាតិ ដើម្បីអាចឱ្យរដ្ឋាភិបាលមួយត្រូវបានបង្កើតឡើង និង កំណត់រយៈពេលកាន់តំណែងជានាយករដ្ឋមន្ត្រីត្រឹមតែ ២អណត្តិ ។
- បង្កើតយន្តការមួយនៅសភា និង ព្រឹទ្ធសភា ដើម្បីដាក់ទណ្ឌកម្មទៅលើសមាជិករដ្ឋាភិបាល សភាជាតិ និង ព្រឹទ្ធសភា ក្នុងករណីដែលពួកគេរំលោភលើក្រមសីលធម៌ ។